ព្រឹត្តិបត្រ BULLETIN

លេខ០០២ | ឆ្នាំទី១ ខែមេសា-មិថុនា ឆ្នាំ២០១៥

ព្រឹត្តិបត្រសម្លេងសហគមន៍ចេញផ្សាយដោយក្រុមអ្នកច្បាប់ និងសិទ្ធិមនុស្សដើម្បីការពារយុត្តិធម៌ជូនជនរងគ្រោះ

# សម្លេងសហគមន៍

SOMLENG SAHAKOM

ការផ្សាយរបស់គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា

CAMBODIAN HUMAN RIGHTS ACTION COMMITTEE

អធិប្បាយលេខនេះ

## ច្បាប់សមាគម និង អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ស្ថិតក្នុងសេរីភាពរឹតត្បិត !

*រឿងរ៉ាវអំពីច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជាមិនមែនជាអ្វីថ្មីទេព្រោះ សេចក្តីព្រាងលើកទីមួយនៃច្បាប់នេះ បានកើតឡើងតាំងពីឆ្នាំ២០១១ ក្នុងពេលដែលច្បាប់នេះនៅមានចន្លោះប្រហោងនៃការរំលោភសិទ្ធិសេរីភាពនិងការផ្តល់ការពន្យល់មិនច្បាស់លាស់។*

ចាប់តាំងពីពេលនោះមក សេចក្តីព្រាងច្បាប់នេះបាន ធ្វើការកែប្រែចំនួន៤ដង រួចមកហើយ តែឥឡូវនេះ សេចក្តីព្រាងច្បាប់ លើកទី៥ ត្រូវបានបញ្ជូនទៅដល់រដ្ឋសភា គឺជាច្បាប់ដែលមានរស់ជាតិដដែល ដូចជាសម្លរម្ជូរត្រីដែលមានរស់ជាតិជូរចត់ ទោះបីកែសម្រួល ឬពិភាក្សាយ៉ាងណាក៏ដោយ ទីបំផុតគឺ គេរក្សា

តទៅទំព័រទី៧

# ច្បាប់គ្រប់គ្រង អង្គការសមាគម មិនមែនរដ្ឋាភិបាលស្ថិតក្នុងកញ្ចប់រដ្ឋាភិបាល !




## មាតិកា

ពលរដ្ឋបាត់បង់ដីធ្លីតាមព្រំដែនដោយសារអ្នកមានអំណាច! ទំព័រ៣

ស្វែងយល់អំពីកម្មសិទ្ធិ ទំព័រ៥

ពលរដ្ឋ១៣នាក់ តំណាងឲ្យ ៣១៨ គ្រួសារប្តឹងទៅរដ្ឋាភិបាល.................... ទំព័រ៨

ទំនាស់ដីធ្លីនៅភូមិសង្គមថ្មីឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់កំពុងដំណើរ.... ទំព័រ១០

កាប់ឈើអស់ប្រគល់ដីឲ្យរដ្ឋវិញជាជំនាញស៊ីរបស់ អ្នកឧកញ៉ា.... ទំព័រ១២

ស្វែងយល់អំពីភោគៈ ទំព័រ១៤

# ព្រឹត្តិបត្រ សម្លេងសហគមន៍

សម្លេងសហគមន៍បង្កើតឡើងដោយក្រុមអ្នកច្បាប់ ស្មគ្រ័ចិត្តមិនរកកម្រៃការពារយុត្តិធម៌ជូនជនរងគ្រោះ។

**សម្លេងសហគមន៍**
គឺជាសម្លេងជនរងគ្រោះ ជាសាររបស់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ដើម្បីស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់ និងជាសម្លេងរបស់សហគមន៍ ជនក្រីក្រដែលទទួលរងនូវការរំលោភបំពានសិទ្ធិដោយពុំទទួលបានយុត្តិធម៌ក្នុងសង្គម ។

សម្លេងសហគមន៍ បន្លឺឡើងក្នុងគោលបំណងផ្តល់ព័ត៌មានដល់ថ្នាក់ដឹកនាំរដ្ឋាភិបាលអំពីភាពរងគ្រោះរបស់ប្រជាពលរដ្ឋដែលរងការគាប់សង្កត់ពីអ្នកមានទ្រព្យសម្បត្តិ និងមន្ត្រីអ្នកមានអំណាច។

**វត្ថុបំណងនៃការបោះពុម្ពព្រឹត្តិបត្រសម្លេងសហគមន៍**
សម្លេងសហគមន៍ គឺជាការផ្សាយរបស់ក្រុមអ្នកច្បាប់ និងសកម្មជនការពារសិទ្ធិមនុស្សពាក់ព័ន្ធការបញ្ចេញមតិ ទស្សនៈ យោបល់ ដែលជាសម្លេងសម្រាប់ប្រឆាំងនូវអំពើអយុត្តិធម៌ ដោយមធ្យោបាយអហិង្សាដែលផ្តោតទៅលើបញ្ហាដីធ្លី និងធនធានធម្មជាតិ។

**សកម្មភាព**
ពង្រឹងសង្គមស៊ីវិល ដីធ្លី និងធនធានធម្មជាតិ តាមរយៈនៃការបោះពុម្ពព្រឹត្តិបត្រសម្លេងសហគមន៍ រយៈពេល ៣ខែ ១លេខ ចំនួន ៣០០០ច្បាប់ ទៅ ១០០០០ច្បាប់ ដែលមានចំនួន ១៦ទំព័រពណ៌ ជាភាសាខ្មែរ។

ចែកផ្សាយព្រឹត្តិបត្រសម្រាប់សមាគម អង្គការដៃគូរ ជាពិសេសសហគមន៍ដែលទទួលរងផលប៉ះពាល់ ពីការរំលោភបំពាន។

មានយុទ្ធសាស្រ្ត ផ្តោតការយកចិត្តទុកដាក់ក្នុងកំរឹតមធ្យម នៃចំណេះដឹងទូទៅរបស់ប្រជាពលរដ្ឋ។

**ចាងហ្វាងការផ្សាយ**
លោក យី សុខសាន្ត ០១៦៨៣៥ ៥៩៧
០១២ ៨៨៣ ៩៨៩

**និពន្ធនាយក**
លោក សួន ប៊ុនសក្តិ ០៩២ ៣៤៤ ៣៥៧

**ជំនួយការនិពន្ធនាយក**
លោក អ៊ាង ពេជ្រ ០១២ ៨៤៨ ១២៤
លោក ស៊ឹង សែនករុណា ០៨៩ ៦៦៦ ៣១២
លោក សឺនជុំសុធន ០១៦ ៣០០ ២២៥

**បច្ចេកទេសកុំព្យូទ័រ**
លោក រដ្ឋា
លោក រតនា

**អ្នកឆ្លើយឆ្លងព័ត៌មាន**
សមាជិកគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា និងសមាជិកសហគមន៍។

# ពលរដ្ឋបាត់បង់ដីធ្លីតាមព្រំដែនដោយសារអ្នកមានអំណាច !

*ពលរដ្ឋបាត់បង់ដីធ្លីតាមព្រំដែន ដោយសារអ្នកមានអំណាច បន្ទាប់ពី កម្ពុជាចាប់ផ្តើមពីមានទំនាស់ព្រំដែនរវាងកម្ពុជា និងថៃ នៅតំបន់ប្រាសាទព្រះវិហារ កាលពីឆ្នាំ២០០៨ រួចមក។ រដ្ឋាភិបាលកម្ពុជាបានបញ្ជូនកងទ័ពជាតិ ជាច្រើនអង្គភាពទៅដាក់ពង្រាយតាមខេត្តជាប់ព្រំដែនខ្មែរ-ថៃ ទៅតាមទីតាំងនៃតំបន់យុទ្ធសាស្ត្រយោធាជាច្រើនកន្លែង តាមបណ្តាខេត្តមួយចំនួន ដូចជា ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និងខេត្តបាត់ដំបង ជាដើម ដើម្បីត្រៀមទប់ទល់ការពារទឹកដីពីសំណាក់កងទ័ពថៃ។*



*សំណល់គ្រឿងផ្ទះ អ៊ុំប្រុស ស្រី ហ៊ាង បន្ទាប់ពីទាហានរុះរើ*

ការដាក់ទីតាំងបន្ទាយកងទ័ពនេះ ទីតាំងកន្លែងខ្លះប៉ះចំលើតំបន់ដីវាលទំនេរ ដីខ្លះជាដីព្រៃរបស់រដ្ឋ ដីខ្លះប៉ះចំភូមិករប្រជាពលរដ្ឋដែលតម្រូវអោយប្រជាពលរដ្ឋផ្លាស់ប្តូរទីលំនៅ និងដីខ្លះទៀតប៉ះចំដីស្រែចំការរបស់ប្រជាពលរដ្ឋ តែគ្មានការដោះដូរ ឬដោះស្រាយអ្វីនោះទេ។ បន្ទាប់ពីបញ្ហាទំនាស់ព្រំដែនមានសភាពធូរស្រាលតំបន់ផ្សេងៗ ដែលបោះទីតាំងបន្ទាយកងទ័ពទាំងនេះ ត្រូវបានខាងយោធាដែលមានបុណ្យសក្តិធំៗ ចាប់ផ្តើមអង្កន់ដីតំបន់ជាប់ទីតាំងបន្ទាយទាំងនោះ ចែកគ្នាចាប់ពីមេទាហានដល់កូនទាហាន ដើម្បីដាំដំណាំទៅតាមស្ថានភាពកំរិតជីវភាពរៀងៗខ្លួន ជាពិសេសមេទាហានធំៗបានដីច្រើន ហើយពួកគាត់នាំគ្នា ដាំដំណាំកៅស៊ូ និងដំណាំដាំម្រេច ដោយមិនបានគិតប្រគល់ដីទាំងនោះមកអោយប្រជាពលរដ្ឋជាម្ចាស់ដីវិញទេ ទើបធ្វើអោយប្រជាពលរដ្ឋមានការមិនពេញចិត្ត ចំពោះទង្វើរបស់ក្រុមមន្ត្រីយោធាដែលធ្វើបែបនេះ ព្រោះថា ពួកគាត់លះបង់ដីទាំងនោះទៅអោយខាងយោធា បោះទីតាំងបន្ទាយកងទ័ពសំរាប់ការពារជាតិ មិនមែនទុកអោយខាងយោធាយកដីពួកគាត់ធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួននោះទេ។ ករណីទាំងនេះ ប្រជាពលរដ្ឋភាគច្រើន មិនហ៊ានប្តឹងផ្តល់អ្វីនោះទេ ពីព្រោះមានការភ័យខ្លាច ហើយបើពួកគាត់ប្តឹងក៏មិនសង្ឃឹមថា ទទួលបានយុត្តិធម៌ដែរ។ ប៉ុន្តែក៏មានប្រជាពលរដ្ឋមួយចំនួនមិនពេញចិត្តនឹងទង្វើរបស់យោធា ដែលយកដីរបស់ពួកគាត់ មកអង្កន់ចែកគ្នា ដោយមិននឹកឃើញពីពួកគាត់ជាម្ចាស់ដីទាល់តែសោះ ក៏ហ៊ានចេញមុខប្តឹងទាមទារដីរបស់ពួកគាត់មកវិញ ប៉ុន្តែដីនោះមិនមែន ស្ថិតនៅក្នុងដីទីតាំងបន្ទាយកងទ័ពនោះទេ។

ជាក់ស្តែងករណីខាងលើនេះ កើតឡើងនៅភូមិថ្មល់កែង ឬក៏ភូមិបំរុងនឹងបង្កើតថ្មីឈ្មោះថា ភូមិតេជោអភិវឌ្ឍន៍ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដែលទីតាំងដីទំនាស់នេះ មានចម្ងាយពីទីរួមខេត្តឧត្តរមានជ័យប្រមាណជាង១០០គីឡូម៉ែត្រ។ មានប្រជាពលរដ្ឋចំនួន១១គ្រួសារ ដែលកំពុងប្តឹងទៅអាជ្ញាធរពាក់ព័ន្ធទាមទារ

យកដីពួកគាត់ទំហំជាង៥០ហិតា ដែលក្នុងចំណោមពួកគាត់ទាំង១១គ្រួសារនេះ សុទ្ធតែបានលះបង់បរិច្ចាកដីទៅឲ្យកងពលតូចអន្តរាគមន៍លេខ២៦ បោះទីតាំងបន្ទាយកងទ័ព កាលពីមានទំនាស់ព្រំដែន។ បន្ទាប់ពីការបរិច្ចាគដីទៅឲ្យខាងយោធាបោះទីតាំងបន្ទាយកងទ័ពរួច ពួកគាត់មើលឃើញដីពួកគាត់នៅសល់ បន្ទាប់ពីខាងយោធាឈូសឆាយព្រំប្រទល់ទីតាំងបន្ទាយរួច ក៏នាំគ្នាបង្កបង្កើនផលរហូតមក ដោយមិនដែលមានបញ្ហាអ្វីកើតឡើងនោះទេ។ លុះដល់ចុងឆ្នាំ២០១២ មានខាងក្រុមនិស្សិតស្ម័គ្រចិត្ត សម្ដេចនាយករដ្ឋមន្ត្រី ចុះបេសកកម្មវាស់វែងដីជូនប្រជាពលរដ្ឋ ហើយក្រុមនិស្សិតក៏បានវាស់វែងធ្វើប្លង់កម្មសិទ្ធិជូនទៅអោយពួកគាត់ទាំង១១គ្រួសារ ដែលជាម្ចាស់ដីនោះគ្រប់ៗគ្នារៀងៗខ្លួន។ ស្រាប់តែដល់ឆ្នាំ២០១៣ ពេលបិទប្រកាសឈ្មោះម្ចាស់កម្មសិទ្ធិទៅជាមានឈ្មោះជនទីបីទៅវិញ ដែលពីមុនមកដីនេះជាដីកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ១១គ្រួសារខាងលើ ព្រមទាំងមិនអនុញ្ញាតឲ្យប្រជាពលរដ្ឋ បង្កបង្កើនផលលើដីនោះទៀតឡើយ ហើយថែមទាំងបានដាក់កម្លាំងទាហានការពារដីឲ្យក្រុមជនទីបីនោះផងដែរ។ ដីរបស់ពួកគាត់ទាំង១១គ្រួសារ នេះត្រូវបានក្រុមលោក **ណាក់ សុខា** មានងារជាឯកឧត្ដម តែមិនស្គាល់ស្ថាប័ន បានឃុបឃិតគ្នាជាមួយមន្ត្រីសុរិយោដីស្រុក និងខេត្ត ដោយមានលោក **សេង សាន្ត** ជាមេបញ្ជាការរងកងពលតូចអន្តរាគមន៍លេខ២៦ ជាអ្នកជួយគាំទ្រពីក្រោយ ហើយបានដាក់កំលាំងទាហានជួយការពារដីមិនអោយប្រជាពលរដ្ឋបានបន្តបង្កបង្កើនផលលើដីពួកគាត់ដូចមុនៗទៀតឡើយ។ រាល់ពេលដែលប្រជាពលរដ្ឋចូលទៅបង្កបង្កើនផលលើដីពួកគាត់ ក្រុមទាហានដែលការពារដីអោយក្រុមលោក **ណាក់ សុខា** នោះ បានបាញ់គំរាម និងបំផ្លាញដំណាំរបស់ពួកគាត់ចោល ដោយមិនមានអាជ្ញាធរណាជួយរកយុត្តិធម៌ជូនពួកគាត់ឡើយ។ ដោយសារភាពអយុត្តិធម៌បែបនេះហើយ ទើបប្រជាពលរដ្ឋដែលរងគ្រោះ ដាក់ពាក្យបណ្ដឹងទាមទារដីពួកគាត់មកវិញទៅស្ថាប័នពាក់ព័ន្ធសុំឲ្យអាជ្ញាធរមានសមត្ថកិច្ចទាំងនោះ ជួយចាត់វិធានការរកដំណោះស្រាយ និងបានដាក់ពាក្យបណ្ដឹងមកសមាគមអាដហុកការពារសិទ្ធិមនុស្ស ដើម្បីជួយ អន្តរាគមន៍រកយុត្តិធម៌តាមផ្លូវច្បាប់។ បច្ចុប្បន្ននេះ ដីទំនាស់ស្ថិតក្នុងភាពប្រទាញប្រទង់គ្នាដាំដំណាំ ដោយមិនទាន់មានការចាត់វិធានការណាមួយរកដំណោះស្រាយជូនប្រជាពលរដ្ឋ ឲ្យបានស្ងប់ចិត្តដោយយុត្តិធម៌នៅឡើយ។



*លោក មាផ លីហួ និងដំណាំសណ្ដែកសៀង*



*ផ្លូវចូលទីបញ្ជាការកងពលតូចអន្តរាគមន៍ លេខ២៦*

# ស្វែងយល់អំពីកម្មសិទ្ធិ

## កម្មសិទ្ធិលើអចលនវត្ថុនៅប្រទេសកម្ពុជា




### តើអចលនវត្ថុជាអ្វី?

តាមន័យសាមញ្ញ និងងាយយល់ អចលនវត្ថុ គឺសំដៅចំពោះ ផ្ទះសម្បែង (សំណង់គ្រប់ប្រភេទ) ដីធ្លី និង វត្ថុគ្រប់ប្រភេទ ដែលជាប់នឹងផ្ទះ ឬដីនោះ។

### តើកម្មសិទ្ធិករមានសិទ្ធិ និងកាតព្វកិច្ចដូចម្តេចខ្លះលើកម្មសិទ្ធិរបស់ខ្លួន?

*អត្ថន័យទូទៅ៖* កម្មសិទ្ធិ គឺជាបណ្តុំនៃសិទ្ធិស្របច្បាប់នានាលើអចលនវត្ថុ រួមមាន៖

- សិទ្ធិប្រើប្រាស់ (ឧ.ប្រើជាលំនៅដ្ឋាន ដាំដំណាំ ឬសកម្មភាពផ្សេងៗដែលច្បាប់មិនហាមឃាត់...)
- សិទ្ធិអាស្រ័យផល (ឧ.ទាញយកផលគ្រប់ប្រភេទ...)
- សិទ្ធិចាត់ចែង (ឧ.សិទ្ធិក្នុងការលក់ដូរ ធ្វើអំណោយ ធ្វើមរតក រុះរើ ឬកំទេចចោល...)

### អំពីប្រភេទនៃកម្មសិទ្ធិ

*កម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ៖* គឺជាកម្មសិទ្ធិផ្ទាល់របស់បុគ្គលម្នាក់ៗ ក្រៅពីរដ្ឋ ឬនីតិបុគ្គលសាធារណៈ ។

*កម្មសិទ្ធិរបស់រដ្ឋ ៖ មាន២ប្រភេទគឺ ៖*

- *កម្មសិទ្ធិឯកជនរបស់រដ្ឋ ៖* គឺជាកម្មសិទ្ធិ លើអចលនវត្ថុទាំងឡាយរបស់រដ្ឋ ប៉ុន្តែមិនស្ថិតក្នុងទ្រព្យជា សម្បត្តិ សាធារណៈរបស់រដ្ឋឡើយ ហើយដែលត្រូវចាត់ចែងដោយរដ្ឋ ដូចកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋដែរ និងអាចជាកម្មវត្ថុនៃកិច្ចការជំនួញបាន។ រដ្ឋ អាចជួល លក់ ដូរ ឬផ្តល់ជាកម្មសិទ្ធិ ដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែល មានសញ្ជាតិជាខ្មែរ ស្របតាមការកំណត់របស់ច្បាប់។

- *កម្មសិទ្ធិសាធារណៈរបស់រដ្ឋ ៖* គឺជាកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយដែលស្ថិតក្នុងទ្រព្យជាសម្បត្តិ សាធារណៈរបស់រដ្ឋ ហើយដែលរដ្ឋត្រូវតែថែរក្សាទុកដោយមិនអាចលក់ដូរ ឬធ្វើអំណោយបានឡើយ។

### អត្ថន័យតាមច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា ៨៥ បានចែងថា ៖

*កម្មសិទ្ធិករនៃទ្រព្យ ជាអចលនវត្ថុ មានសិទ្ធិប្រើប្រាស់អាស្រ័យផល និងចាត់ចែងទ្រព្យរបស់ខ្លួនផ្តាច់មុខ និងទូលំទូលាយកុំឱ្យតែយកទ្រព្យនោះ ទៅប្រើប្រាស់ក្នុងបទណាមួយដែល ច្បាប់បានហាមឃាត់។*

*មាត្រា៨ នៃច្បាប់នេះក៏បានបញ្ជាក់ផងដែរ អំពីបុគ្គលទាំងឡាយដែលមានសិទ្ធិក្លាយជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា គឺលុះត្រាតែបុគ្គលនោះមានសញ្ជាតិជាខ្មែរ។*

# សារៈសំខាន់នៃការមានកម្មសិទ្ធិ

### តើកម្មសិទ្ធិមានគុណសម្បត្តិយ៉ាងណា?

*កម្មសិទ្ធិផ្តល់ និងជួយឱ្យប្រជាពលរដ្ឋ ៖*

- មានភាពសុខដុមរមនា លើកស្ទួយជីវភាពរស់នៅ ឱ្យមានភាពកាន់តែប្រសើរឡើង
- មានជំរករស់នៅសមរម្យ មានអាហារហូបចុក និងសំភារៈប្រើប្រាស់គ្រប់គ្រាន់
- មានប្រភពចំណូលមួយភាគធំ សំរាប់ទ្រទ្រង់ជីវភាពរស់នៅ

### ផលប៉ះពាល់នៃការគ្មានកម្មសិទ្ធិ ឬការបាត់បង់កម្មសិទ្ធិ

*ផលប៉ះពាល់ដែលអាចកើតមានឡើងចំពោះគ្រួសារដែលគ្មានកម្មសិទ្ធិមានដូចជា ៖*

- ការបាត់បង់ទីជម្រក និងសេចក្តីថ្លៃថ្នូរ
- ការខ្វះខាតចំណីអាហារ និងសម្លៀកបំពាក់
- ការខ្វះលទ្ធភាពក្នុងការថែរក្សាសុខភាព
- កូនមិនបានទៅរៀន ឬបោះបង់ការសិក្សា
- ការបែកបាក់ក្រុមគ្រួសារ
- ចំណាកស្រុក
- ការប្រព្រឹត្តបទល្មើស ឬអំពើអនាចារផ្សេងៗ

### វិធីសាស្ត្រ និងការថែរក្សាកម្មសិទ្ធិ

*ដើម្បីថែរក្សាកម្មសិទ្ធិ ប្រជាពលរដ្ឋគួរៈ*

- ខិតខំប្រមូល និងថែរក្សានូវឯកសារភស្តុតាង វត្ថុតាង និងសាក្សីនានា ដើម្បីបញ្ជាក់អំពីការកាន់កាប់ និងសិទ្ធិទាំងឡាយលើកម្មសិទ្ធិរបស់ខ្លួន។
- បោះបង្គោលកំណត់ព្រំដីឱ្យបានច្បាស់លាស់
- ចេះចងក្រង រួមសហការជួយគ្នាទៅវិញទៅមក ក្នុងការការពារតវ៉ាទាមទារកម្មសិទ្ធិស្របច្បាប់របស់ខ្លួន និងប្រឆាំងរាល់អំពើដកហូតដោយខុសច្បាប់ផ្សេងៗ ដូចជាការប្រើអំណាចការប្រើឥទ្ធិពលសំឡុតគំរាមកំហែងជាដើម ។

### តើពលរដ្ឋអាចទទួលបានកម្មសិទ្ធិដោយវិធីណា?

តាមច្បាប់ភូមិបាលឆ្នាំ២០០១ អនុញ្ញាតឱ្យប្រជាពលរដ្ឋយកធ្វើជាកម្មសិទ្ធិនូវដី និងសំណង់គ្រប់ប្រភេទទាំងអស់ ដោយគ្មានការកំរិតពីបរិមាណ ឬទំហំដី ឬទ្រព្យជាអចលនវត្ថុឡើយ។

ជាគោលការណ៍នៃច្បាប់ភូមិបាលឆ្នាំ២០០១ ប្រជាពលរដ្ឋអាចទទួលបាននូវកម្មសិទ្ធិតាមលក្ខណៈពីរយ៉ាងធំៗ គឺ៖

*ការបានជាកម្មសិទ្ធិឯកជននៅលើដីឯកជនរបស់រដ្ឋគឺ ៖*

ទី១ ៖ តាមរយៈការចែកឱ្យជាអំណោយដល់ប្រជាពលរដ្ឋដោយរដ្ឋ និងប្រជាពលរដ្ឋ។

ទី២ ៖ តាមរយៈសម្បទានដីសង្គមកិច្ចសំរាប់ប្រជាពលរដ្ឋក្រីក្រ ដើម្បីសង់លំនៅដ្ឋានរស់នៅ ឬធ្វើកសិកម្មចិញ្ចឹមជីវិត ។

ទី៣ ៖ តាមរយៈការចូលទៅកាន់កាប់លើផ្នែកណាមួយនៃដីឯកជនរបស់រដ្ឋក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិតាមរយៈភោគៈ ។

*ការបានជាកម្មសិទ្ធិឯកជន តាមមធ្យោបាយឯកជនរបស់ប្រជាពលរដ្ឋគឺ ៖*

ទី១ ៖ តាមរយៈការលក់-ទិញដីជាកម្មសិទ្ធិស្របច្បាប់រវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ។

ទី២៖ តាមរយៈការប្តូរដីជាមួយនឹងដី ឬអចលនៈវត្ថុផ្សេងៗ ប៉ុន្តែមិនប្រើមាសប្រាក់ដើម្បីទិញទេ។

ទី៣ ៖ តាមរយៈការឱ្យអំណោយជាដី ឬផ្ទះដែលជាកម្មសិទ្ធិរបស់ជនណាម្នាក់ដល់ជនម្នាក់ទៀត

ទី៤ ៖ តាមរយៈសន្តតិកម្ម (ការចែកមរតក) ដោយមានបណ្តាំ ឬឥតបណ្តាំពីម្ចាស់ទ្រព្យដែលបានស្លាប់។

> សំគាល់៖ ប៉ុន្តែច្បាប់ភូមិបាលឆ្នាំ២០០១ បានហាមឃាត់ការចូលកាន់កាប់លើផ្នែកណាមួយនៃដីឯកជនរបស់រដ្ឋ ក្នុងបំណងយកធ្វើជាកម្មសិទ្ធិតាមរយៈភោគៈ ចាប់ពីថ្ងៃដែលច្បាប់ភូមិបាលថ្មី ចូលជាធរមាន នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។

# សិទ្ធិក្នុងការធានាចំពោះការដកហូតកម្មសិទ្ធិឯកជន

> មាត្រា៥ នៃច្បាប់ភូមិបាលថ្មីបានដកស្រង់ខ្លឹមសារនៃគោលការណ៍សិទ្ធិនេះ ចេញពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដោយចែងថា "គ្មានបុគ្គលណាមួយ ត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើទៅតាមទំរង់ និងនីតិវិធី បញ្ញត្តិដោយច្បាប់ និងបទបញ្ជា បន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌" ។

គោលការណ៍នេះអនុញ្ញាតឱ្យតែអាជ្ញាធរដែលតាងនាមរដ្ឋប៉ុណ្ណោះ ដើម្បីអនុវត្ត និងបំរើប្រយោជន៍សាធារណៈ ក្នុងកាលៈទេសៈដែលមានការអនុញ្ញាតដោយច្បាប់តែប៉ុណ្ណោះ។ ប្រសិនបើអាជ្ញាធរដែលមិនតាងនាមរដ្ឋយកគោលការណ៍នេះទៅប្រើ មានន័យថាគាត់ប្រព្រឹត្តអំពើខុសច្បាប់ និងត្រូវផ្តន្ទាទោសទៀតផង ។

*តមកពីទំព័រមុខ*

# ច្បាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ស្ថិតក្នុងសេរីភាពរឹតត្បិត !

ខ្លឹមសារដដែល ។

បើរដ្ឋាភិបាលនៅតែប្រកាន់ជំហរបែបនេះ អង្គការ សមាគម មិនមែនរដ្ឋាភិបាលនៅកម្ពុជានឹងបាត់ស្រមោលដោយសារតែការរឹតត្បិតនិងគៀបសង្កត់ ធ្វើឲ្យពួកគាត់មានការធុញទ្រាន់នឹងនីតិវិធីដ៏ស្មុគស្មាញ និងមានចរិតនយោបាយរបស់រដ្ឋាភិបាល ស្របតាមបញ្ញត្តិនានានៅក្នុងច្បាប់នេះ។ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលដែលមាននិន្នាការឯករាជ្យមិនពាក់ព័ន្ធនឹងនយោបាយនឹងលែងមានវត្តមាន ហើយមានតែសមាគម និងអង្គការដែលមានទំនាក់ទំនង និងបំរើផលប្រយោជន៍ឲ្យរដ្ឋាភិបាលប៉ុណ្ណោះដែលអាចឈរជើងនៅកម្ពុជាបាន។

ដើម្បីផ្តល់ជូននូវការប្រមើរមើលអំពីអនាគតនៃសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា សូមពិនិត្យមើលមាត្រា៥ នៃសេចក្តីព្រាងទី៥ នៃច្បាប់ស្តីពីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ មាត្រា៥ កំណត់ចំនួនសមាជិក៥នាក់ជាតម្រូវចាំបាច់ក្នុងការបង្កើតអង្គការមួយ ដែលក្នុងពេលបច្ចុប្បន្នមានតម្រូវការតែបុគ្គលម្នាក់អាចស្នើសុំបង្កើតអង្គការមួយបាន ហើយមាត្រា៨ កំណត់អំពីថាតើរដ្ឋាភិបាលនឹងអនុញ្ញាត ឬមិនអនុញ្ញាតចំពោះការស្នើរចុះឈ្មោះអង្គការ សមាគម ក្នុងពេលដែលស្ថានភាពបច្ចុប្បន្នមិនមានភាពចាំបាច់ ហើយមាត្រា១០ នឹងតម្រូវឲ្យអង្គការសមាគមទាំងអស់ត្រូវបង្ហាញឲ្យច្បាស់លាស់នូវព័ត៌មានអំពីថវិកាដែលមាននៅក្នុងគណនីធនាគារទៅឲ្យរដ្ឋាភិបាល។ សំណាងដែរដែលមាត្រាទាំងនេះ ចែងសម្រាប់តែអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ប៉ុន្តែអង្គការអន្តរជាតិ និងស្ថាប័នអ្នកផ្តល់ជំនួយអន្តរជាតិនានាក៏ទំនងជាត្រូវចាកចេញពីប្រទេសកម្ពុជាដោយសារតែច្បាប់នេះដែរ ដោយសារតែគេមិនអាចគោរពបាននូវកាតព្វកិច្ចនានាដែលចែងក្នុងសេចក្តីច្បាប់នេះដែលតម្រូវឲ្យ “**យល់ព្រមពីអជ្ញាធរសាធារណៈ**” អំពីគោលបំណងនៃគម្រោងរបស់គេ ដូចដែលមាត្រា១៥បានកំណត់។

បើសិនជាច្បាប់ នេះត្រូវបានអនុម័ត តើអ្វីទៅជាលទ្ធផលសម្រាប់ប្រជាជនកម្ពុជា? គឺផលវិបាកទីមួយ លំហរសេរីភាព សម្រាប់ការស្ទួរដេញដោលជាសាធារណៈ និងការបញ្ចេញមតិពីផ្នែកផ្សេងៗគ្នា នៃសង្គមកម្ពុជានឹងត្រូវកាត់បន្ថយយ៉ាងគំហុក ហើយការទទួលយកចំពោះការរិះគន់លើគោលនយោបាយរបស់រដ្ឋាភិបាល នឹងមានកាន់តែរួមតូចទៅៗ រីឯការគាបសង្កត់កាន់តែខ្លាំងពីសំណាក់មន្ត្រីសាធារណៈទាក់ទងនឹងទំនាស់ផ្សេងៗក៏នឹងកាន់តែចុះថយទៅៗ។ ផលវិបាកទីពីរ សហគមន៍ជាច្រើននឹងត្រូវរងគ្រោះពីការខ្វះថវិកា សម្ភារៈប្រើប្រាស់បម្រើឲ្យសកម្មភាពរបស់ខ្លួន ឬក៏ផលិតកម្មស្បៀងអាហារចាំបាច់ដែលរដ្ឋាភិបាលមិនអាចផ្តល់ជូននាពេលបច្ចុប្បន្ន។ កម្មវិធីអប់រំ កម្មវិធីសុខភាព ការងារសង្គមនឹងទំនងជារលាយបាត់ស្រមោល ឬកាន់តែរួញតូចទៅៗ ដោយសារតែពួកគេមិនអាចទទួលបានថវិកាជំនួយពីអ្នកផ្តល់ជំនួយអន្តរជាតិនានា។ ផលវិបាកទីបី សហគមន៍ដាច់ស្រយាល ដូចជាជនជាតិដើមភាគតិច ដែលពួកគេមានការលំបាកក្នុងការរស់នៅរួចជាស្រេចហើយនោះនឹងកាន់តែឯកោ ឬក៏កាន់តែត្រូវគេបំភ្លេច ដែលការនេះនឹងបង្ករឲ្យមានភាពគ្រោះថ្នាក់សម្រាប់ពួកគេ ហើយបន្ទាប់មកគឺជីវភាពរបស់ពូកគេ និងប្រពៃណី ជាពិសេស គឺបាត់បង់បេតិកភ័ណ្ឌទាំងមូលរបស់កម្ពុជា។ ឯផលវិបាកចុងក្រោយដែលនឹងកាន់តែលំបាកសម្រាប់ប្រជាជនកម្ពុជា និងសហគមន៍របស់ពួកគេ គឺការទទួល និងផ្តល់ព័ត៌មាន អំពីការព្រួយបារម្ភរបស់ខ្លួនទៅអាជ្ញាធររដ្ឋាភិបាលដើម្បីទទួលបានការគាំទ្រខាងផ្លូវច្បាប់ប្រសិនបើពួកគេមានតម្រូវការ។

បញ្ហាទាំងនេះគ្រាន់តែជាចំណែកតិចតួចមួយ នៃបណ្តាផលវិបាកជាច្រើនដែលច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលអាចបង្ករឡើងប្រសិនបើច្បាប់នេះត្រូវបានអនុម័ត និងដាក់ឲ្យប្រើប្រាស់មែននោះ។ ប៉ុន្តែអ្វីដែលរឹតតែអាក្រក់ជាងនេះទៀតនោះគឺវានឹងនាំការពុកផុយដល់សង្គមស៊ីវិលដែលកំពុងធ្វើសកម្មភាពដ៏ប្រពៃ និងប្រកបដោយធនធានដែលជាសរសរស្តម្ភមួយនៅក្នុងសង្គមប្រជាធិបតេយ្យទំនើប។

យើងនឹងមិនទទួលយកនូវសេចក្តីព្រាងច្បាប់ដែលមានខ្លឹមសារដូចស្ថានភាពបច្ចុប្បន្ននេះទេ ដោយសារច្បាប់នេះនឹងនាំយើងទៅកាន់ស្ថានការមួយដែលកាន់តែលែងមានភាពប្រាកដប្រជា ហើយទីបំផុតអ្នករងគ្រោះគឺយើងទាំងអស់គ្នាដែល ជាពលរដ្ឋកម្ពុជា។ រដ្ឋាភិបាលត្រូវទទួលយកនូវការព្រួយបារម្ភរបស់យើងពីព្រោះប្រទេសនេះជាប្រទេសរបស់ពួកយើងដែរមិនមែនជា កម្មសិទ្ធិរបស់បក្សណាមួយឡើយ។

*ទស្សនៈសហគមន៍*

# ពលរដ្ឋ១៣នាក់តំណាងឲ្យ ៣១៨គ្រួសារប្តឹងទៅរដ្ឋាភិបាលឲ្យអន្តរាគមន៍ទៅក្រុមហ៊ុនUDG

*ប្រជាពលរដ្ឋពីជាង ១០០០គ្រួសារ ដែលរស់នៅក្នុង ស្រុកពីរ គឺ ស្រុក បូទុមសាគរនិង ស្រុកគីរីសាគរ ខេត្ត កោះកុងទទួលរងនូវផលប៉ះពាល់ យ៉ាងធ្ងន់ធ្ងរ បន្ទាប់ពីរដ្ឋាភិបាល បានផ្តល់ដីសម្បទានសេដ្ឋកិច្ចជួលរយៈពេលវែងឲ្យទៅក្រុមហ៊ុន Union Development Group Co, Ltd (ក្រុមហ៊ុនចិន) នៅក្នុងឆ្នាំ ២០០៨ មក ពលរដ្ឋដែលរស់នៅតំបន់នោះវេទនាដូច របប ប៉ុល ពត គឺ ពួកគេត្រូវបានជម្លៀសចេញ មួយចំនួនពីភូមិកំណើតឲ្យទៅនៅតំបន់ភ្នំ ដីខ្សាច់ គ្មានទឹក គ្មានភ្លើង គ្មានផ្លូវថ្នល់ គ្មានមន្ទីរពេទ្យ សាលារៀនៗលៗ មិនតែប៉ុណ្ណោះ ពួកគាត់ទទួលរងនូវការធ្វើទុកបុកម្និញពីសំណាក់អាជ្ញាធរ និងសន្តិសុខក្រុមហ៊ុន ដូចជា រុះរើ ដុតបំផ្លាញ ផ្ទះសម្បែងរបស់ពួកគាត់ទាំងបង្ខំ ដែលពួកគាត់មិនពេញចិត្ត ។ ការទាមទារតវ៉ា របស់ពួកគាត់ គឺប្រឈមទៅនឹងការគំរាមកំហែង ចាប់ដាក់ពន្ធនាគា តាមផ្លូវតុលាកា ។*

ការផ្តល់ដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុនចិន UDG ដែលមានផ្ទៃដីទំហំ ៣៦០០០ហិកតារយៈពេល៩៩ឆ្នាំ គឺជាលើកទីមួយ ដែលមហាក្សត្រចុងក្រោយ កាត់ដីឱទ្យានជាតិឲ្យទៅក្រុមហ៊ុនចិន តាមរយៈនៃការស្នើសុំពីរាជរដ្ឋាភិបាល។


មេការក្រុមហ៊ុន UDG

ការតស៊ូមតិតាមរយៈនៃការដើរដាក់ពាក្យបណ្តឹងតាមស្ថាប័នពាក់ពន្ធ័ រហូតដល់មានពេលខ្លះ បិទផ្លូវ ក៏មិនមាន ដំណោះស្រាយឡើយ។ ការតស៊ូរបស់ពួកគាត់ មានគ្រួសារខ្លះបែកបាក់គ្នាហើយ ទីបញ្ចប់ត្រូវបានបោះបង់ដីចោល ព្រោះតែជីវភាព។

ការទាមទារតស៊ូ ក្រាញ ននៀលរបស់ពលរដ្ឋក្នុង តំបន់នោះ ចាប់តាំងពីជាង ១០០០គ្រួសារ បច្ចុប្បន្ន សល់តែ ៣១៨ គ្រួសារ សុខចិត្តស្លាប់លើដីកំណើតរបស់ខ្លួន។



បើតាមរបាយការណ៍ ចុងក្រោយ ប្តឹងទៅនាយករដ្ឋមន្ត្រី តាមរយៈ ឯកឧត្តម **វ៉ាន់ សំអឿន** ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលស្នើសុំឲ្យសម្តេច ជួយអន្តរាគមន៍រកយុត្តិធម៌ ឲ្យកាត់ឆ្វៀលដី ជូនពួកគាត់ដែលតស៊ូប្តូរផ្តាច់នោះ គឺនៅសល់ ១២ ភូមិ ក្នុងនោះមាន៖





១- ភូមិ កៀន ក្រឡាញ់ (ពយមង) ឃុំភ្លីមាស មានផ្ទះ ៥ ខ្នង មានដីទំហំ៨៤ហិកតា ក្នុងចំណោម ៨គ្រួសារដែលមិនទាន់ទទួលបានសំណង ស្មើនឹងដីសរុប ១៣៦ ហិកតា។

២- ពយជប៉ុន ភូមិព្រែកស្មាច់ ឃុំកោះស្តេច មាន១០ខ្នងផ្ទះ ក្នុងចំណោម៣៧គ្រួសារ ដែលមិនទាន់ទទួលយកសំណងទូទាត់ ជាប្រាក់ ជាដីថ្មី និងជាផ្ទះថ្មីនៅឡើយ ក្នុងនោះដីភូមិមានទំហំ ៣៥ហិកតា (រួមទាំងដីសាលារៀន និងវត្ត១០ហិកតា) និងដីរបស់២៧គ្រួសារ ដែលមិនមានផ្ទះ មាន៣០១ហិកតា។

៣- ភូមិភ្លីមាស ឃុំភ្លីមាសមាន៧ផ្ទះ និងមានដីទំហំ ៣៧ហិកតា ក្នុងចំណោម ៣៩ គ្រួសារ មានដីស្មើនឹង ១៣២ហិកតា រួមទាំងដីចំការ។

៤- ភូមិតានី ឃុំភ្លីមាស មាន១២ផ្ទះ មានដីទំហំ ១២៦ហិកតា ក្នុងចំណោម ២៦ គ្រួសារមានដីទំហំ ស្មើនឹង២២៦ ហិកតា។

៥- ភូមិសំរ៉ុងតាកែវ ឃុំព្រែកខ្សាច់ មាន៧៤ គ្រួសារ ប៉ះពាល់ដីទំហំ ៦៥៧ហិកតា ក្នុងនោះមាន ៥៣ផ្ទះមានដីទំហំ៥៥៤ ហិកតា

៦- ភូមិយាយសែន ប៉ះពាល់ដីស្រែ ៣០គ្រួសារ ប៉ះពាល់ដីទំហំ ១១៣ហិកតា។

៧- ភូមិចម្លងគោ ប៉ះពាល់ដីប្រជាពលរដ្ឋ ៣២គ្រួសារ លើទំហំដី ១០២,៩០ហិកតា ក្នុងនោះនៅចំណុចកៀនទឹក មាន១៧ ខ្នងផ្ទះដែលមានដីទំហំ៤៧,៩០ហិកតា។

៨- ភូមិពាមកាយ ឃុំកោះស្តេច ស្រុកគិរីសាគរ ប៉ះពាល់ដីប្រជាពលរដ្ឋចំនួន ២៦គ្រួសារ លើទំហំដី១៦៥ហិកតា ក្នុងនោះមាន ១៩ខ្នងផ្ទះលើទំហំដី៦៦ហិកតា(ពយឡាំធាន ១០គ្រួសារ កៀនប្រង់៧គ្រួសារ និងពាមកាយ២គ្រួសារ)។

៩- ភូមិតានូន ឃុំតានូន ស្រុកបុទុមសាគរ ប៉ះពាល់ដី៣៣គ្រួសារ លើទំហំដី២៥៤ ហិកតា។

១០- ភូមិបាក់រនាស់ ឃុំតានូន ស្រុកបុទុមសាគរ ប៉ះពាល់ដីទំហំ ៣៦ហិកតា និងផ្ទះ១ខ្នង។

១១- ភូមិព្រែកខ្យង ឃុំតានូន ស្រុកបុទុមសាគរ ប៉ះពាល់ដី១១គ្រួសារ លើទំហំដី៣៩,៩០ ហិកតា។

១២- ភូមិព្រែកស្វាយ ឃុំតានូន ស្រុកបុទុមសាគរ ប៉ះពាល់ ៦គ្រួសារ លើទំហំដី៦២ហិកតា និងផ្ទះ១ខ្នង។

បើតាមលិខិត បំភ្លឺ លេខ ២៥៩ ស ជ ណ ប ស្ត ចុះថ្ងៃ ១២ ខែ មីនា ឆ្នាំ ២០១៥ របស់ ឯកឧត្តម **សាយ សំអាល់** បំភ្លឺទៅរដ្ឋសភា គឺហាក់ដូចជាខិតខំប្រឹងប្រែងណាស់សម្រាប់ប្រជាពលរដ្ឋ ប៉ុន្តែបើពិនិត្យជាក់ស្តែង គឺមិនសូវអើពើប៉ុន្មានទេ ហើយក្នុងលិខិតនោះ បញ្ជាក់ថា មិនមានការបង្ខិតបង្ខំ ពលរដ្ឋនោះគឺខុសពីការពិត ហើយ បើមិនជឿអាចបើកវេទិកាឬ សវនាការ ហើយអញ្ជើញឲ្យពលរដ្ឋមកសួរឆ្លើយតទល់គ្នា អាចដឹងរឿងពិតជាមិនខាន។

ពលរដ្ឋជាច្រើនគ្រួសារ សំណូមពរដំទទូចដល់រាជរដ្ឋាភិបាលកម្ពុជាឲ្យឈប់ការបណ្តេញពលរដ្ឋជាតិខ្លួនឯង ចេញយកដីឲ្យបរទេស។

# ទំនាស់ដីធ្លីនៅភូមិសង្គមថ្មីឃុំថ្មដា ស្រុក វាលវែង ខេត្តពោធិសាត់កំពុងដំណើរការដោះស្រាយ

*ទំនាស់ដីធ្លីដែលកើតឡើងនៅចុងឆ្នាំ ២០១០ រវាងប្រជាពលរដ្ឋនៅភូមិ សង្គមថ្មី ជាមួយ ក្រុមហ៊ុន MDS កំពុងស្ថិតលើក្រុមការងារដែលមានអាជ្ញាធរ និងសង្គមស៊ីវិលរួមគ្នាដោះស្រាយ ។*



*អាជ្ញាធរស្រុកវាលវែង សហការជាមួយអង្គការសង្គមស៊ីវិលចុះសម្រង់ព័ត៌មាន*

យោងតាមបណ្តឹង ដែលប្រជាពលរដ្ឋដាក់ចូល អង្គការសង្គមស៊ីវិល នៅក្នុងឆ្នាំ២០១០ ( តែក្នុងភូមិសង្គមថ្មី) ពលរដ្ឋមានចំនួន ៨៤ គ្រួសារដែលមានទំហំដីប៉ះពាល់ ចំនួន ៩៥០ ហិកតា ដែលពួកគេបានបញ្ជាក់ថា ពួកគេបានកាន់កាប់តាំងពីឆ្នាំ១៩៩៨ ហើយ ឯកសារដែលពួកគេមាន គឺបង្កាន់ដៃទទួលពាក្យ ឆ្នាំ ១៩៩៨-៩៩ ខ្លះឆ្នាំ ២០០០រីឯពាក្យស្នើសុំកាន់កាប់ ក៏ដូចគ្នាដែរ ហើយ ក្រុមហ៊ុនមកធ្វើការឈូសឆាយថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ ទំនាស់ក៏ចាប់ផ្តើមពីពេលនោះមក។ បើតាមបណ្តឹងបីភូមិ ប្រជាពលរដ្ឋ គឺភូមិសង្គមថ្មី ភូមិកណ្តាល ភូមិឯកភាព ឃុំថ្មដាស្រុកវាលវែង ខេត្តពោធិសាត់ មានពលរដ្ឋ ៣៧៩ គ្រួសារ ដែលប្រកបមុខរបបស្រែចំការបានប្តឹងរួមដែរមកអង្គការសង្គមស៊ីវិល ដោយពួកគាត់ខ្លាចក្រុមហ៊ុន MDS រំលោភយកដីរបស់គាត់។ ការតស៊ូមតិចាប់តាំង ពីឆ្នាំ២០១០ រហូតមកដល់ពេលនេះនៅសល់តែ ២៣គ្រួសារ តែប៉ុណ្ណោះ ដែលពួកគាត់ បានដើរដាក់ពាក្យបណ្តឹង ទៅគ្រប់ស្ថាប័ន ពាក់ពន្ធ័ រីឯនីតិវិធីក្នុងការដោះស្រាយកំពុងស្ថិតនៅលើអាជ្ញាធរខេត្តដោយមានការសហការជាមួយអង្គមស៊ីវិល។

បើតាមកាស្រាវជ្រាវ និងអង្កេតរបស់អង្គការសង្គម ស៊ីវិល សំរាប់២៣គ្រួសារ ហើយការកាន់កាប់របស់ពួកគាត់ ជាក់ស្តែងប្រហែល ជិត ២០០ហិកតា ហើយពួកគាត់អាស្រ័យផល ជាក់ស្តែង ប្រហែល ១០០ហិកតា តែប៉ុណ្ណោះ។

ក្រោយមក ក្នុង ចំណោម ២៣គ្រួសារ មានគ្រួសារ០១ទទួល យកសំណង និងគ្រួសារ ០១ទៀត ស្ថិតនៅក្រៅក្រុមហ៊ុន ដូច្នេះ នៅសល់

តែ ២១គ្រួសារតែប៉ុណ្ណោះដែលត្រូវដោះស្រាយបញ្ចប់។

នីតិវិធីក្នុងការដោះស្រាយនោះ គឺ ខេត្ត បានរៀបចំទម្រង់ជាសលកបត្រព័ត៌មាន ដើម្បីសម្រង់ ព័ត៌មាន អំពីសវតានៃការកាន់កាប់និងឲ្យពលរដ្ឋ បង្ហាញអំពីឯកសារដែលពួកគាត់មាន។ ការសម្រង់ព័ត៌មាន ត្រូវបានពន្យាពេល ច្រើនលើក ច្រើនសារនោះ ដើម្បីទុកឲ្យពលរដ្ឋ មានឱកាស ឲ្យពលរដ្ឋបានរៀបឯកសារដាក់មកក្រុមការងារដើម្បីធ្វើការផ្ទៀងផ្ទាត់គ្នាងាយស្រួលក្នុងការដោះស្រាយ។



*ការទាមទារតវ៉ារបស់ពលរដ្ឋ ឃុំថ្មដា ស្រុកវាលវែង*



*ក្រុមការងារអង្គការសង្គមស៊ីវិលជួបជាមួយអាជ្ញាធរស្រុកវាលវែង*

*កំប្លែង*

## ដូចជេមហាក្សត្រ !

អាហារថ្ងៃត្រង់នៃគ្រួសារមួយ ហូបបណ្តើរ មើលទូរទស្សន៍ ពេលសម្រាកថ្ងៃអាទិត្យ

**កូន:** ឪ! ខ្ញុំឃើញអាទូរទស្សន៍មួយនោះជេរអនុប្រធានសភា អស់ទាស់!
**ឪ:** កូន ឯងកុំចេះ រឿងអ្នកនយោបាយ
**ម្តាយ:** មិនដឹងជាស្អីទេ! ឪកូនគេនេះ។
**កូន:** ឪ! ក្រែង តំណាងរាស្ត្រមហាក្សត្រតែងតាំង?
**ឪ :** ត្រូវហើយកូន!
**កូន:** អញ្ចឹង! បើគេជេរតំណាងរាស្ត្រ ដូចជេមហាក្សត្រ!

*ដោយ សុខ*

---

*កំប្លែង*

## គេមានចេតនាទេដឹង !

រដ្ឋាភិបាលដែលដឹកនាំដោយសម្តេច គឺធ្វើអ្វីបាននិង សូម្បីខ្មែរក្រហមក្បាលរឹងក៏សម្តេចបំបែកបានដែរគ្មានឧបសគ្គឡើយ ដោយរលូន ។

**នាយចយ:** រលូនស្អី ធ្វើតែអត្តសញ្ញាណប័ណ្ណឲ្យពលរដ្ឋប្រើមិនបានផងហ្នឹង !
**នាយ ចំ :** ពលរដ្ឋយើង ដែលពេញវ័យប្រហែល ១០លានាក់ បើរដ្ឋាភិបាលមានចេតនាចង់ធ្វើឲ្យពលរដ្ឋ ប្រើងាយបំផុត !
**នាយចយ :** បើងាយដូច នាយចំ ឯងថាមែន គេធ្វើបាត់ទៅហើយ មិនទុកឲ្យពលរដ្ឋវេទនាដើរអត់មានអត្តសញ្ញាណនោះដូចពលរដ្ឋ អត់សញ្ជាតិ អត់ប្រទេសនោះទេ!
**នាយចំ :** អញ្ចឹង ប្រហែលគេមានចេតនាទេដឹង?

*ដោយ លំអង់ពេជ្រ*



# កាប់ឈើអស់ប្រគល់ដីឲ្យរដ្ឋវិញជាជំនាញស៊ីរបស់ អ្នកឧកញ៉ា ក្រុមហ៊ុន និងអ្នកមានបច្ចុប្បន្ន !

*បច្ចុប្បន្ន ព្រៃឈើរបស់ខ្មែរ រាប់សិបលានហិកតាត្រូវបាន រដ្ឋាភិបាល ផ្តល់សម្បទានដីសេដ្ឋកិច្ចឲ្យទៅក្រុមហ៊ុន ដើម្បីធ្វើការអភិវឌ្ឍន៍ ក្នុងគោលបំណង បានផលិតផលនាំចេញ ប្រាក់ចំណូលចូលរដ្ឋ ពលរដ្ឋមានការងារ ធ្វើមានប្រាក់ចំណូល។ ប៉ុន្តែការផ្តល់សម្បទានដីបច្ចុប្បន្នមាន តែ នាយ ផ្លក់ និង នាយ ផ្លយ ទេដែលដឹងថា គេផ្តល់ដីស៊ីយ៉ាងម៉េច !*

**ផ្លយ៖** ផ្លក់ ! ការផ្តល់ដីសម្បទានសេដ្ឋកិច្ចតាមគ្នាដឹង គឺរកការងារឲ្យពលរដ្ឋធ្វើដើម្បីបានប្រាក់ ចំណូល ហ្នឹង ? រឿងអីស៊ីតាមជំនាញ ?

**ផ្លក់៖** យឺ! គ្រាន់តែប៉ុណ្ណឹង មិនយល់ ដែរមានឃើញរដ្ឋាភិបាល ផ្តល់កាន់តែច្រើន ពលរដ្ឋអត់ការងារធ្វើឬអត់ ? ម៉្យាងទៀតពលរដ្ឋពលរដ្ឋកំពុងនាំគ្នាសំរុកធ្វើលិខិតឆ្លងដែនដើម្បីទៅស្វែងរកការងារធ្វើនៅក្រៅប្រទេសដែរ ឬ អត់ ? អាហ្នឹង! គេហៅថាស៊ីតាមជំនាញនោះ !

**ផ្លយ៖** ផ្លក់ ! ការផ្តល់ដី ក្រៅពីការងារ និងចំណូល តើគេមានជំនាញស៊ីអ្វីទៀត ?

**ផ្លក់៖** គេស៊ីតាមរយៈធ្វើជាប្រជាទិចុត ព្រោះអ្នកនយោបាយ គេឆ្លាត នៅពេលដែលមិនទាន់មានអ្នកចេះ ព្រោះគេរៀបចំធ្វើជាសម្បទានដី ចែកគ្នីគ្នាសំរាប់បក្សពួកគេ រាប់ពាន់ រាប់ម៉ឺនហិកតា ហើយគេកំណត់យកពន្ធចាប់ពីឆ្នាំទី១០ឬទី១៥ គឺល្មមបើមានឈើ គឺកាប់ឈើអស់ ហើយបើរដ្ឋាភិបាល ចង់ដកហូតដីយកវិញ ក៏ដកទៅចុះ ព្រោះគេកាប់ឈើអស់ហើយហ្នឹង។



ម៉្យាងទៀតការផ្តល់សម្បទានដីពេលខ្លះ ជាន់លើដីរបស់ប្រជាពលរដ្ឋដែលកំពុងអាស្រ័យផល រួចពួកគេប្តឹងពលរដ្ឋចាប់ពលរដ្ឋដាក់ជាថ្នូរទៅនឹងដីទើបគេឲ្យរួចខ្លួនវិញ។

**ផ្លយ៖** ផ្លក់! គេធ្វើអញ្ចឹង ធ្វើស្អី ន៎ ?

**ផ្លក់៖** ផ្លយ ឯងប៉ុណ្ណឹងក៏ឆ្ងល់ដែរ! អាហ្នឹងហើយដែរគេហៅថាស៊ីតាមជំនាញ។

**ផ្លយ៖** ផ្លក់! ចុះជុំនាញស៊ីតាមរយៈ ប្រជាភិថុត នោះគេស៊ីរបៀបយ៉ាងម៉េច? ជាពិសេស ពាក់ពន្ធ័ដីធ្លី!

**ផ្លក់៖** ពិបាក់ គិតស្អី ពួកអ្នកកាន់អំណាចបច្ចុប្បន្ន គេចែកដីគ្នាកាន់កាប់ តាមរយៈដីសម្បទានសេដ្ឋកិច្ច ពួកគេដូចធ្វើនំអត់ម្សៅ អញ្ចឹងអត់ចេះខាតទេ បានដីមកកាប់តែឈើលក់ក៏បានដែរ ហើយបើរដ្ឋាភិបាលចង់រឹតត្បិតគាប់សង្កត់ ពន្ធ ពួកគេអាចប្រគល់ដីឲ្យវិញ ហើយគ្រាន់តែធ្វើបាយការណ៍ថាក្សយ័ធន់គឺជាការស្រេច។ ម៉្យាងទៀត ការដែលពួកគេប្រមូលដីយកមកកាន់កាប់អស់ ធ្វើឲ្យពលរដ្ឋខ្វះដី ពួកគេនឹងប្រគល់ និងបែងចែកដីជូនពលរដ្ឋវិញជាថ្នូរ នឹងសន្លឹកឆ្នោតដែលគេហៅថាប្រជាពិថុតនោះអី! ដោយពេលវេណាខ្លី គ្នាគិតលាផ្លយឯងត្រឹមនេះ សិនចុះចាំជួបគ្នាលេខក្រោយទៀត។

*ដោយ សុខ*



# ស្វែងយល់អំពីភោគៈ

## តើភោគៈមានន័យដូចម្តេច ?

តាមន័យទូទៅ ភោគៈ គឺសំដៅចំពោះអំពើរបស់ប្រជាពលរដ្ឋ ក្នុងការចូលកាន់កាប់លើដីឯកជនរបស់រដ្ឋ ដើម្បីយកមកធ្វើជាកម្មសិទ្ធិពិតប្រាកដរបស់ខ្លួន ។ ហេតុនេះដែលហៅថាភោគៈនោះ គឺជាសភាពការណ៍មួយដែល មានន័យថាកិរិយាកាន់កាប់នូវវត្ថុអ្វីមួយយ៉ាងផ្ទាច់មុខតែឯង និងបំពេញចំពោះវត្ថុនោះនូវកិច្ចការទាំងឡាយដូចដែលកម្មសិទ្ធិករបានបំពេញដែរ ។

**កំណត់សំគាល់**

ភោគៈ គឺជាអំពើនៃការកាន់កាប់ ដែលមិនទាន់ក្លាយជាកម្មសិទ្ធិពេញលេញនៅឡើយ។ ភោគៈ គឺកិរិយាកាន់កាប់នូវដីឯកជនរបស់រដ្ឋ ក្នុងបំណងយកជាកម្មសិទ្ធិផ្តាច់មុខតែម្នាក់ឯង និងបំពេញចំពោះដីនោះនូវកិច្ចការទាំងឡាយ ដូចជាកម្មសិទ្ធិករបំពេញដែរ។

## ភោគៈតាមច្បាប់ភូមិបាល

### លក្ខណៈនៃភោគៈកន្លងមក

ក្នុងមាតិកាទី២ ត្រង់ជំពូកទី៤ ច្បាប់ភូមិបាល យើងអាចពិនិត្យឃើញថា ប្រជាពលរដ្ឋបានកាន់កាប់ជា ភោគៈក្នុងរយៈពេលខុសៗគ្នា ហើយច្បាប់ក៏បានទទួលស្គាល់នូវរាល់ភោគៈទាំងនេះ ។

#### *ក. ភោគៈដែលច្បាប់ទទួលស្គាល់តាំងពីឆ្នាំ ១៩៨៩*

មាត្រា ២៩ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ បានចែងថា ភោគៈនៃអចលនវត្ថុដែលត្រូវបានទទួលស្គាល់ ចាប់ពីឆ្នាំ១៩៨៩ អាចបង្កើតជាពិសេសនូវសិទ្ធិភណ្ឌិក (សិទ្ធិភណ្ឌិក មកពីពាក្យថា "សិទ្ធិ" + "ភ័ណ្ឌ" ទំនងជាមានន័យថា សិទ្ធិនានាលើអចលន វត្ថុដូចជា គឺសិទ្ធិផ្ទេរដាក់បន្ទុកជាដើម) លើអចលនវត្ថុ និងនាំទៅដល់លទ្ធកម្មនៃ កម្មសិទ្ធិ (ការបានជាកម្មសិទ្ធិ) ដោយអ្នកកាន់កាប់ទ្រព្យក្នុងលក្ខខណ្ឌ ដែលបានកំណត់ដោយច្បាប់ភូមិបាល។ តាមន័យនេះប្រជាពលរដ្ឋទាំងឡាយដែលមានភោគៈ ហើយដែលត្រូវបានច្បាប់ទទួលស្គាល់រួចហើយនោះ នឹងទទួល បានជាកម្មសិទ្ធិស្ថាពរលើទ្រព្យរបស់ពួកគេ ។

*__មាត្រា២៩__ ក្នុងក្របខ័ណ្ឌ នៃការបង្កើតឡើងវិញនូវកម្មសិទ្ធិលើអចលនវត្ថុនៅកម្ពុជា ក្រោយសម័យ មានវិបត្តិ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដោយមិនចំណុះទៅនឹងវិធានទូទៅ នៃអាជ្ញាយុកាលស្តីពីកម្មសិទ្ធិ លើចលនវត្ថុភោគៈនៃអចលនវត្ថុដែលត្រូវបានទទួលស្គាល់ចាប់ពីឆ្នាំ១៩៨៩ អាចបង្កើតជាពិសេស នូវសិទ្ធិភណ្ឌិក លើអចលនវត្ថុ និងនាំទៅដល់លទ្ធកម្ម នៃកម្មសិទ្ធិដោយអ្នកកាន់កាប់ទ្រព្យក្នុងលក្ខខណ្ឌ ដែលបានកំណត់ដោយច្បាប់នេះ។ ការចូលកាន់កាប់ភោគៈ ត្រូវបញ្ចប់នៅពេលដែលច្បាប់នេះ ចូលជាធរមាន។*

#### *ខ. ភោគៈដែលបានកាន់កាប់យ៉ាងតិច ៥ឆ្នាំ*

ដោយសារច្បាប់ភូមិបាលឆ្នាំ១៩៩២ បានអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលកាន់កាប់ប្រើប្រាស់ដី ឯកជនរបស់រដ្ឋ ដើម្បីធ្វើជាភោគៈរបស់ខ្លួន ទើបមានប្រជាពលរដ្ឋមួយចំនួនបានចូលកាន់កាប់ដី ក្រោយឆ្នាំ១៩៨៩ រហូតមកហើយ បើគិតមកទល់ពេលនេះ ដីឯកជនរបស់រដ្ឋទាំងនោះបានក្លាយជាភោគៈស្របច្បាប់របស់ពួកគាត់ទៅហើយ គ្រាន់តែ ពួកគាត់ពុំទាន់បានទៅស្នើសុំប័ណ្ណកាន់កាប់នៅឡើយ ។ ទោះជាយ៉ាងណាក្តីច្បាប់ភូមិបាលឆ្នាំ២០០១ ក៏បានទទួល ស្គាល់ភោគៈប្រភេទនេះផងដែរ ព្រមទាំងបានផ្តល់សិទ្ធិដល់បុគ្គលទាំងឡាយ ដែលបានអាស្រ័យផលនៃភោគៈដោយ សន្តិវិធី និងមិនមានការជំទាស់ដើម្បីស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ ។

***ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ៣០ ចែងថា៖***

*បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពីប្រាំឆ្នាំ យ៉ាងតិច គិតដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះលើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវតាម ច្បាប់ក្នុងការកាន់កាប់ជាឯកជនមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ ។*

*ក្នុងករណីមានការជំទាស់ដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិស្ថាពរនេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថា ខ្លួនឯង ផ្ទាល់បានបំពេញលក្ខខណ្ឌនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពីប្រាំឆ្នាំនៅលើអចលន វត្ថុដែលមានទំនាស់ ឬយកភស្តុតាងដែលថា ខ្លួនបានទិញអចលនវត្ថុនោះពីភាគីដើម ឬពីសិទ្ធិវន្តស្របច្បាប់ ឬអ្នកទទួលផ្ទេរកម្មសិទ្ធិ ឬពីសន្តតិជនរបស់ខ្លួន។*

#### *គ. ភោគៈដែលមានរយៈពេលតិចជាង ៥ឆ្នាំ*

ស្រដៀងគ្នានឹងចំណុចខាងលើដែរ ប្រជាពលរដ្ឋមួយចំនួនបានកាន់កាប់ភោគៈរបស់ខ្លួនមិនទាន់គ្រប់រយៈពេល៥ឆ្នាំនៅឡើយ ប៉ុន្តែពួកគាត់បានចូលកាន់កាប់មុនពេលច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមាន។ ភោគៈប្រភេទនេះ ត្រូវបានច្បាប់អនុញ្ញាតឱ្យបន្តការកាន់កាប់រហូតគ្រប់រយៈពេលស្របច្បាប់៥ឆ្នាំ ដើម្បីបានប័ណ្ណកម្មសិទ្ធិស្ថាពរលើទ្រព្យរប

ស់ពួកគេ។

***ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៣១ ចែងថា៖***

*បុគ្គលដែលបានអាស្រ័យផលនៃភោគៈកន្លងមក គិតមកដល់កាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន ប្រសិនបើបានបំពេញគ្រប់គ្រាន់នូវលក្ខខណ្ឌទាំងឡាយក្នុងការក្លាយទៅជាកម្មសិទ្ធិករ អាចត្រូវបានអនុញ្ញាត ដោយអាជ្ញាធរមានសមត្ថកិច្ចឱ្យបន្ថែមរយៈពេលកាន់កាប់ភោគៈរបស់ខ្លួនរហូតគ្រប់រយៈពេលស្របច្បាប់ប្រាំឆ្នាំ និងបានប័ណ្ណកម្មសិទ្ធិស្ថាពរ។ ការអនុញ្ញាតឱ្យបន្តរយៈពេលមិនអាចត្រូវបានបដិសេធដោយអាជ្ញាធរមានសមត្ថកិច្ចឡើយ ប្រសិនបើភោគៈបានមកដោយសន្តិវិធី និងមិនមានការជំទាស់ ។*

ដូច្នេះ ប្រជាពលរដ្ឋទាំងឡាយដែលមានភោគៈ ដូចបានរៀបរាប់ខាងលើត្រូវបានច្បាប់ទទួលស្គាល់ជាភោគី ស្របច្បាប់លើអចលនវត្ថុដែលខ្លួនមាន ទោះបីជាការកាន់កាប់នោះមានរយៈពេលខ្លីប៉ុនណាក្តី ឱ្យតែការកាន់កាប់នោះធ្វើឡើងមុនពេលច្បាប់ភូមិបាលថ្មីចូលជាធរមាន។

## ជំហាន និងលក្ខខណ្ឌតម្រូវនៃភោគៈ

ដើម្បីឈានទៅដល់ការបានជាកម្មសិទ្ធិលើទ្រព្យដែលខ្លួនមាន មាត្រា៣៨ នៃច្បាប់ភូមិបាលឆ្នាំ២០០១ បាន ចែងអំពី លក្ខខណ្ឌតម្រូវនៃភោគៈ ថា ភោគីត្រូវតែកាន់កាប់ដីធ្លីនោះដោយ៖

- ពិតប្រាកដ
- គ្មានហិង្សា
- ដឹងឮជាសាធារណៈ
- គ្មានអាក់ខាន
- សុចរិត



### ជំហាននៃការក្លាយជាកម្មសិទ្ធិតាមរយៈភោគៈ




កំណត់សំគាល់: ការចូលកាន់កាប់ភោគៈ ត្រូវធ្វើមុនថ្ងៃទី៣០ សីហា ២០០១ ។

## សិទ្ធិនានារបស់ភោគី

### សិទ្ធិនានារបស់ប្រជាពលរដ្ឋចំពោះភោគៈស្របច្បាប់របស់ខ្លួន






ឧបត្ថម្ភដោយ

OXFAM

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា
The Cambodian Human Rights Action Committee (CHRAC)
ADHOC - BCV - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP - IDA
KKKHRDA - KID - KIND - KSA - KYA - LAC - PDP -PJJ - VIGILANCE

អាសយដ្ឋានៈ ផ្ទះលេខ ៩Eo ផ្លូវលេខៈ ៣៣០, ខណ្ឌចំការមន, ភ្នំពេញ | ទំនាក់ទំនងអ៊ីម៉េលៈ chracsecretariat@yahoo.com
ទូរស័ព្ទ: 023 301 415/ 023 305 609 | ទូរសារ: 023 218 759 | គេហទំព័រ: www.chrac.org

ចំនួន ៣២៧០ច្បាប់